**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

## សារលិខិតជូនពរ

## សម្តេចកត្តាព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា

**សម្តេចកត្តាព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

នៅក្នុងឱកាសដ៏ឧត្តុង្គឧត្តម ប្រពៃថ្លៃថ្លាដែល **សម្តេចកត្តាព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ទទួលបាន« **សញ្ញាបត្រថ្នាក់បណ្ឌិតកិត្តិយស ផ្នែកអក្សរសាស្ត្រ** » ពីសាកលវិទ្យាល័យក្វាងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៧ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង ពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ និងក្នុងនាមខ្លួនខ្ញុំនិងភរិយាខ្ញុំ សូមសម្តែងនូវមនោសញ្ចេតនា សោមនស្សរីករាយ ឥតឧបមា អបអរសាទរយ៉ាងក្លៀវក្លាបំផុត ចំពោះ **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** ដែលទទួលបាននូវ « **សញ្ញាបត្រថ្នាក់បណ្ឌិតកិត្តិយស ផ្នែកអក្សរសាស្ត្រ** » ពីសាធារណរដ្ឋប្រជាមានិតចិន គឺពិតជាផ្តល់នូវមហាកិត្តិយស ដ៏ឧត្តុង្គឧត្តម សម្រាប់ប្រទេសជាតិនិងប្រជាជនកម្ពុជាទាំងមូល និងជាការឆ្លើយតបយ៉ាងស័ក្តិសមបំផុត ចំពោះស្នាដៃរបស់ **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** ក្នុងការខិតខំប្រឹងប្រែងដឹកនាំ កាកបាទក្រហមកម្ពុជា ទទួលបានជោគជ័យជាបន្តបន្ទាប់ រួមចំណែកជាមួយរាជរដ្ឋាភិបាល លើកកម្ពស់វិស័យអប់រំ សង្គមកិច្ចនិងការអភិវឌ្ឍប្រទេសជាតិ លើគ្រប់វិស័យ ជាពិសេសការបម្រើប្រទេសជាតិមាតុភូមិនិងប្រជាជនក្នុងផ្នែកមនុស្សធម៌ និងការលើកស្ទួយតម្លៃស្ត្រីខ្មែរ ទទួលបានកិត្យានុភាព មោទនភាពជាតិ លើឆាកអន្តរជាតិ។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ សូម **សម្តេចកត្តាព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ឧត្តមភរិយា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា **ព្រមទាំង បុត្រា បុត្រី បុត្រប្រសា ចៅប្រុស ចៅស្រី** ជាទីស្រឡាញ់ សូមជួបតែនឹងពុទ្ធពរបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកត្តាព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី ស្តីទី**

នាយឧត្តមសេនីយ៍ **ចាយ សាំងយុន**

វិថីហ្សកឌីមីត្រូវ ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៩៖ General@mod.gov.comUSER